អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

## មាតិកា៖

- ៨៨លានដុល្លារទទួលបានពីដំណើរកម្សាន្តក្នុងស្រុកនៃពិធីបុណ្យអុំទូក
- AMRO សេដ្ឋកិច្ចនឹងកើនឡើង ២.៨% នៅឆ្នាំនេះ
- តម្លៃស្រូវធ្លាក់ចុះនៅឆ្នាំនេះ ធ្វើឱ្យកសិករខេត្តស្វាយរៀង មិនសូវចំណេញ
- អង្គការទេសចរណ៍ពិភពលោក ជួយផ្សព្វផ្សាយការលើកលែងចត្តាឡីស័កអ្នកដំណើរចាក់វ៉ាក់សាំងមកកម្ពុជា
- អតិរេកពាណិជ្ជកម្មរបស់ឥណ្ឌូនេស៊ី សម្រាប់ខែតុលា ឆ្នាំ២០២១ (គិតជាពាន់លានដុល្លារ)
- ពាណិជ្ជកម្មវៀតណាម សម្រាប់ពាក់កណ្ដាលខែចុងក្រោយ នៃខែកញ្ញា ឆ្នាំ២០២១ (គិតជាពាន់លានដុល្លារ)
- អត្រាភាពគ្មានការងារធ្វើរបស់ប្រទេសថៃឈានដល់កម្រិត២,២៥%នៅក្នុងត្រីមាសទី៣
- កម្ពុជាអាចនាំទំនិញនិងផលកសិកម្មត្រង់ទៅចិនដោយមិនឆ្លងកាត់ប្រទេសទី៣ដូចមុន
- រាជរដ្ឋាភិបាលនៃប្រទេសឡាវគ្រោងនឹងចំណាយថវិកាជាង ១០០លានដុល្លារដើម្បីជំរុញផលិតកម្មក្នុងស្រុក
- ចិនគ្រោងទិញកសិផលពីតំបន់អាស៊ានទ្វេដងក្នុងទឹកប្រាក់១៥០ពាន់លានដុល្លារនៅ៥ឆ្នាំខាងមុខ
- ក្រុមសមាជិកសភាមកពីគណបក្សប្រជាធិបតេយ្យ ជំរុញឱ្យលោកប្រធានាធិបតី Joe Biden បញ្ចេញប្រេងបម្រុង និងដាក់បម្រាមការនាំចេញប្រេង
- សហរដ្ឋអាមេរិកដាក់សម្ពាធក្រុមប្រទេសផលិតប្រេង OPEC+ បូមប្រេងបន្ថែម


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមវរ: អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ៨៨លានដុល្លារទទួលបានពីដំណើរកម្សាន្តក្នុងស្រុកនៃពិធីបុណ្យអុំទូក



*ប្រភព៖ Hong Menea, Phnom Penh Post ២០២១*

កម្ពុជាប្រមូលផលបានជាង ៨៨លានដុល្លារ ពីការធ្វើដំណើរក្នុងស្រុកចំនួន ១,១៤៧,៣៥៩ នាក់ ដែលប្រព្រឹត្តឡើងចាប់ពីថ្ងៃទី ១៥ដល់២១ ខែវិច្ឆិកា ក្នុងឱកាសបុណ្យអុំទូក ដែលជាសញ្ញាវិជ្ជមាននៃការងើបឡើងវិញសម្រាប់ឧស្សាហកម្មទេសចរណ៍ ដែលជាប់គាំងដោយវិបត្តិកូវីដ១៩អស់រយៈពេលជិត០២ឆ្នាំ។

តាមរយៈអ្នកនាំពាក្យក្រសួងទេសចរណ៍ អ្នកសម្រាកលំហែកាយ បានចំណាយលើអាហារ កន្លែងស្នាក់នៅ និងសេវាកម្មទេសចរណ៍ផ្សេងៗទៀតក្នុងពិធីបុណ្យអុំទូក ហើយភ្ញៀវទេសចរខ្មែរដែលធ្វើដំណើរពីរយប់បីថ្ងៃត្រូវចំណាយពី ៥០ទៅ៨០ដុល្លារ ចំណែកជនបរទេសអាចចំណាយចន្លោះពី ៩០ទៅ៩៥ដុល្លារ ក្នុងមួយថ្ងៃ។ ខណៈដែល ការស្រាវជ្រាវរបស់សមាគមភ្នាក់ងារទេសចរណ៍កម្ពុជា អ្នកធ្វើដំណើរដែលទៅលេងរមណីយដ្ឋានទេសចរណ៍ក្នុងអំឡុងពេលបុណ្យទានធំៗ ជាទូទៅមានរយៈពេល ២ឬ៣ថ្ងៃ ជាពិសេសនៅតាមគោលដៅសំខាន់ៗ ដូចជា ក្រុងសៀមរាប ព្រះសីហនុ និងកំពត អាចឡើងថ្លៃហូតដល់ ៨០ទៅ១២០ដុល្លារក្នុងមនុស្សម្នាក់។ ក្រសួងទេសចរណ៍បានរាយការណ៍ថា ចាប់ពីថ្ងៃទី១៥ ដល់២១ ខែវិច្ឆិកា ការធ្វើដំណើរក្នុងស្រុកចំនួន ១០២ ១៦៧នាក់ ត្រូវបានធ្វើដំណើរទៅកាន់ខេត្តកំពតនាតំបន់មាត់សមុទ្រនៃព្រះរាជាណាចក្រកម្ពុជា។ ខណៈដែលរាជធានីភ្នំពេញ មានចំនួន ២០៣ ៤៥៤នាក់ និងខេត្តព្រះសីហនុ ១៤៥ ០៤២នាក់ សៀមរាប ១៤១ ២១៩នាក់ ខេត្តកែប ៩២ ៥៣៨នាក់ និងពោធិ៍សាត់ ៧៥ ៥៧៨នាក់។ ទន្ទឹមនឹងនេះ ឯកឧត្តម **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ មានប្រសាសន៍ថា ការកើនឡើងនៃវិស័យទេសចរណ៍ក្នុងស្រុករយៈពេលជិតមួយសប្តាហ៍បានស្តារឡើងវិញនូវទំនុកចិត្ត របស់អ្នកធ្វើដំណើរនាពេលខាងមុខ ហើយបានបង្កើតលំហូរសេដ្ឋកិច្ចដ៏សំខាន់ចូលទៅក្នុងសហគមន៍ក្នុងស្រុក និងទូទាំងប្រទេស ខណៈដែលប្រតិបត្តិករទេសចរណ៍ចាប់យកឱកាសយ៉ាងច្រើនពីការងើបឡើងវិញកាន់តែឆាប់រហ័សនេះ។ *ដោយវត្តា វង្សវឌ្ឍនៈ*

*ប្រភព៖ Phnom Penh Post ចេញផ្សាយថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១*

### AMRO សេដ្ឋកិច្ចនឹងកើនឡើង ២.៨% នៅឆ្នាំនេះ



*ប្រភព៖ Michael Firn, Khmer Times ២០២១*

យោងតាមការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣(AMRO) សេដ្ឋកិច្ចរបស់កម្ពុជា នឹងងើបឡើងវិញពីការធ្លាក់ចុះ ៣.១%កាលពីឆ្នាំមុន បន្ទាប់ពីយុទ្ធនាការចាក់វ៉ាក់សាំងប្រកបដោយជោគជ័យបានអនុញ្ញាតឱ្យរោងចក្របើកដំណើរការឡើងវិញ បន្ធូរបន្ថយការស្ទះខ្សែសង្វាក់ផ្គត់ផ្គង់និងជួយបង្កើនការនាំចេញ។

AMRO លើកឡើងថា ការងើបឡើងវិញពីជំងឺរាតត្បាតត្រូវបានគេរំពឹងថានឹងទទួលបានសន្ទុះជាបណ្ដើរៗក្នុងឆ្នាំ២០២១ ទោះបីជាមានការរីករាលដាលនៃការឆ្លងមេរោគជាសកលក៏ដោយ។ ទោះបីជាការផ្ទុះឡើងបានកាត់បន្ថយសកម្មភាពសេដ្ឋកិច្ចក៏ដោយ ក៏ប្រទេសកម្ពុជាត្រូវបានព្យាករណ៍ថានឹងកើនឡើង ២.៨% នៅឆ្នាំ ២០២១ ដោយការងើបឡើងវិញដ៏រឹងមាំនៃផ្នែកផលិតកម្ម ដែលត្រូវបានជំរុញដោយការកើនឡើងនៃតម្រូវការសម្លៀកបំពាក់ និងការនាំចេញផលិតផលផ្សេងទៀត ខណៈដែលតម្រូវការសកលកើនឡើង។

ជាមួយគ្នានេះ បើទោះបីជាកម្ពុជាបានប្រកាសបើកប្រទេសឡើងវិញទាំងស្រុងសម្រាប់អាជីវកម្ម ប៉ុន្តែ AMRO បានព្រមានថា សម្រាប់ប្រទេសមួយពឹងផ្អែកខ្លាំងលើវិស័យទេសចរណ៍ និង ហ្វូងកម្មកររោងចក្រដ៏ធំ ការងើបឡើងវិញនៃកូវីដ១៩ អាចនឹងសម្លាប់ការងើបឡើងវិញបណ្ដោះអាសន្ន។ ប៉ុន្តែការបន្តការបិទខ្ទប់ និងការឆ្លងឡើងវិញ ដែលមិនអាចគ្រប់គ្រងបានអាចបណ្ដាលឱ្យមានការខូចខាតយ៉ាងធ្ងន់ធ្ងរដល់អាជីវកម្មសេវាកម្មជាច្រើន ក៏ដូចជាក្រុមហ៊ុននាំចេញផងដែរ។

ដោយឡែក ក្រុមស្រាវជ្រាវដែលមានមូលដ្ឋាននៅប្រទេសសិង្ហបុរីក៏បានណែនាំដល់រដ្ឋាភិបាលឱ្យយកចិត្តទុកដាក់លើការរក្សា និងការកែលម្អគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពរបស់ខ្លួនក្នុងការធានានូវសំណាញ់សុវត្ថិភាពសង្គមសម្រាប់ជនក្រីក្រ និងគ្មានការងារធ្វើការវិនិយោគបន្ថែមលើវិស័យថែទាំសុខភាព និងការអប់រំ និងនាំមកនូវកំណែទម្រង់រចនាសម្ព័ន្ធ ដើម្បីជួយវិស័យដែលទំនងជាចូលរួមចំណែកភាគច្រើនក្នុងការរស់ឡើងវិញនៃសេដ្ឋកិច្ចកម្ពុជា។*ដោយ វត្តា វង្សវឌ្ឍនៈ*

*ប្រភព៖ Khmer Times ចេញផ្សាយថ្ងៃទី២៣ ខែវិច្ឆិការ ឆ្នាំ២០២១*

## កម្ពុជាអាចនាំទំនិញនិងផលកសិកម្មត្រង់ទៅចិន



*ដោយ កម្ពុជាថ្មី*

ប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានមានប្រសាសន៍ថា កម្ពុជាកំពុងចរចាជាកញ្ចប់ ចំពោះការនាំចេញទំនិញ និងផលកសិកម្មដោយត្រង់ទៅប្រទេសចិន។ កន្លងទៅទំនិញរបស់កម្ពុជាមួយចំនួន ចេញពីកម្ពុជាឆ្លងកាត់ប្រទេសទី៣ ឥឡូវត្រូវទៅផ្ទាល់។ ដូច្នេះធ្វើឱ្យកម្ពុជារបស់យើងមានលទ្ធភាពកាន់តែច្រើន ក្នុងការពង្រឹងនូវវិស័យកសិកម្ម និងការនាំចេញនូវផលិតផលកសិកម្មទៅក្រៅប្រទេស ដែលចិនចំណែកដ៏ធំក្នុងនាំចេញ និងអឺរ៉ុបក៏យើងនាំចេញសម្រាប់អង្ករល្អ។ នាយករដ្ឋមន្ត្រីចិនចាប់អារម្មណ៍លើមៀនប៉ៃលិន ឬតាង៉ែន ដោយចិននឹងផ្តល់លក្ខណៈពិសេស ត្រួតពិនិត្យគុណភាពតាមប្រព័ន្ធអនឡាញ។

នាឱកាសសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការស្ពានឆ្លងទន្លេមេគង្គ ស្ពានមិត្តភាពកម្ពុជា-ចិន ស្ទឹងត្រង់-ក្រូចឆ្មារ ប្រមខុរាជរដ្ឋាភិបាលកម្ពុជា បានជម្រាបឯកអគ្គរដ្ឋទូតចិនប្រចាំនៅកម្ពុជាថា នៅខេត្តកំពង់ចាម ជាតំបន់សំបូរចេកច្រើនជាងគេ(ចេកចម្ការលើ និងស្ទឹងត្រង់)។

កម្ពុជា និងចិនបានប្តេជ្ញាបង្កើនទំហំពាណិជ្ជកម្មទ្វេភាគីដល់ ១០ពាន់លានដុល្លារនៅឆ្នាំ ២០២៣ ពោលគឺ

កាលពីឆ្នាំ ២០២០ មាន ៨,១៣ន់លានដុល្លារ បាន ធ្លាក់ចុះ ៥,២%ធៀបនឹងឆ្នាំ ២០១៩។ កម្ពុជានាំចេញ ទំនិញទៅកាន់ប្រទេសចិនក្នុងត្រីមាសទី៣បានកើន ឡើង៥២%។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖កម្ពុជាថ្មី ចេញផ្សាយថ្ងៃអង្គារទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១។*

## ADB អនុម័តប្រាក់កម្ចី ១៨០លានដុល្លារ កែលម្អហេដ្ឋារចនាសម្ព័ន្ធក្រុងបាវិត, ក្រុងកំពត និងក្រុងប៉ោយប៉ែត




ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានអនុម័តប្រាក់កម្ចី ចំនួន១៨០លានដុល្លារជួយដល់ក្រុងចំនួន៣នៅកម្ពុជា (ក្រុងបាវិត កំពត និងប៉ោយប៉ែត) ធ្វើឱ្យប្រសើរនូវហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងបង្កើនលទ្ធភាពប្រកួតប្រជែង ផ្នែកសេដ្ឋកិច្ច។ អ្នកឯកទេសអភិវឌ្ឍន៍ទីក្រុងរបស់ADB បានថ្លែងថា «ប្រជាពលរដ្ឋកម្ពុជា កាន់តែច្រើនកំពុង ផ្លាស់ទីលំនៅទៅកាន់ក្រុងលំដាប់ទីពីរ [secondary cities] ប៉ុន្តែ លទ្ធភាពទទួលបានហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទីក្រុង រួមទាំងបរិស្ថានមិនសូវល្អ បានធ្វើ ឱ្យជីវភាពរស់នៅកាន់តែពិបាក និងប៉ះពាល់ ដល់ កំណើនសេដ្ឋកិច្ចទីក្រុង»។ ដូច្នេះ«គម្រោងនេះ នឹង ជួយរាជរដ្ឋាភិបាល ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រង ទឹកស្អាត អនាម័យ និងកាកសំណល់ និង ជនងាយរងគ្រោះផ្នែកសុខភាព សេដ្ឋកិច្ច និង ផលប៉ះពាល់បរិស្ថាន ដោយសារអនាម័យមិនល្អ។ ក្រុងបាវិត និង ប៉ោយប៉ែត គឺជាច្រកចូលទៅកាន់ ប្រទេសវៀតណាម និង ប្រទេសថៃ ហើយទីក្រុងកំពង់ផែកំពត បានក្លាយជាគោលដៅទេសចរណ៍។ យុទ្ធសាស្រ្តភាពជាដៃគូប្រចាំប្រទេសរបស់ ADB សម្រាប់កម្ពុជា ឆ្នាំ ២០១៩-២០២៣ គាំទ្រដល់កំណើនសេដ្ឋកិច្ចនៅ តាមច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូងនៃមហាអនុ តំបន់មេគង្គ ដែលរួមមានក្រុងបាវិត កំពត និងប៉ោយប៉ែត។ គម្រោងនេះ ក៏នឹងបង្កើតផែនទីបង្ហាញផ្លូវ ដើម្បី បង្កើនការប្រមូលចំណូលដោយរដ្ឋបាលក្រុង ដែល កំពុងពឹងផ្អែកយ៉ាងខ្លាំងលើប្រាក់ឧបត្ថម្ភធន ពីរដ្ឋបាល ថ្នាក់ជាតិ ដើម្បីផ្តល់សេវាកម្ម។ ផែនទីបង្ហាញផ្លូវនឹង រួមបញ្ចូលកំណែទម្រង់ពន្ធគយដើម្បីចំណាយលើប្រតិបត្តិការ និងការថែទាំទីក្រុង និងផែនការដើម្បីធានា បាននូវ ការផ្តល់សេវា ប្រកបដោយប្រសិទ្ធភាព រួមទាំងការវាយ តម្លៃអំពីឱកាសសម្រាប់ការចូលរួមពីវិស័យ ឯកជន។ គម្រោងថ្មីរបស់ ADB នេះ នឹងត្រូវបានគាំទ្រដោយ ជំនួយបច្ចេកទេសចំនួន២ លានដុល្លារ ពីមូលនិធិជប៉ុន សម្រាប់ការកាត់បន្ថយភាពក្រីក្រ (Japan Fund for Poverty Reduction)។ ជំនួយបច្ចេកទេសនេះនឹងផ្តោតលើការអភិវឌ្ឍ ទីក្រុងប្រកបដោយនិរន្តរភាព និងភាពធន់នឹងអាកាសធាតុ រួមទាំងការធ្វើឱ្យប្រសើរឡើងនូវផែនការប្រើប្រាស់ដី ក៏ដូចជាសមត្ថភាពស្ថាប័ន និង អភិបាលកិច្ច។ ធនាគារអភិវឌ្ឍន៍អាស៊ី នឹងធ្វើការ ជាមួយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្នុងការសម្របសម្រួល ជាមួយទីក្រុង ក៏ដូចជាក្រសួង ដែលពាក់ព័ន្ធ ដើម្បីធ្វើកំណែទម្រង់ច្បាប់ និងគោល នយោបាយជាតិ។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ freshnews ចេញផ្សាយថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១។*

## អង្គការទេសចរណ៍ពិភពលោក ជួយផ្សព្វផ្សាយពីការលើកលែងចត្តាឡីស័កសម្រាប់អ្នកដំណើរចាក់វ៉ាក់សាំងមកកម្ពុជា



អង្គការទេសចរណ៍ពិភពលោក (UNWTO) បានជួយផ្សព្វផ្សាយអំពីការលើកលែងការធ្វើចត្តាឡីស័កសម្រាប់អ្នកដំណើរទាំងអស់ដែលបានចាក់វ៉ាក់សាំងរួចដែលមកដល់ប្រទេសកម្ពុជា។ អ្នកដំណើរទាំងអស់ដែលបានចាក់វ៉ាក់សាំងពេញលេញ ចូលមកដល់កម្ពុជាតាមច្រកអន្តរជាតិទាំងអស់ (ផ្លូវគោក ផ្លូវអាកាស ផ្លូវទឹក) ឈប់តម្រូវឱ្យធ្វើចត្តាឡីស័កទៀតហើយ។ ដើម្បីទទួលបានការលើកលែងនេះ អ្នកដំណើរចាក់វ៉ាក់សាំងទាំងនេះត្រូវផ្តល់ ៖

១៖ វិញ្ញាបនបត្រចាក់វ៉ាក់សាំងពេញលេញ។

២៖ វិញ្ញាបនបត្រ ឬលិខិតបញ្ជាក់លទ្ធផលធ្វើតេស្ត PCR អវិជ្ជមាន រយៈពេល៧២ម៉ោង។

វិញ្ញាបនបត្រ ឬលិខិតបញ្ជាក់ខាងលើ ត្រូវចេញ និងទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសដើម។ ពេលមកដល់ច្រកអន្តរជាតិ អ្នកដំណើរត្រូវធ្វើតេស្តរហ័ស ដោយត្រូវរង់ចាំលទ្ធផលពី ១៥នាទី ទៅ ២០នាទី។ បើលទ្ធផលអវិជ្ជមាន អ្នកដំណើរអាចធ្វើដំណើរកម្សាន្តពេញផ្ទៃប្រទេសកម្ពុជា។

សម្រាប់អ្នកដំណើរដែលមិនទាន់ចាក់វ៉ាក់សាំង ត្រូវធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ បន្ទាប់ពីធ្វើតេស្តរហ័សនៅច្រកអន្តរជាតិ។

រដ្ឋមន្ត្រីក្រសួងទេសចរណ៍ បានបង្ហាញសុទិដ្ឋិនិយមលើការជួយផ្សព្វផ្សាយបន្ថែមរបស់អង្គការទេសចរណ៍ពិភពលោក អំពីការសម្របសម្រួលក្នុងការទទួលភ្ញៀវទេសចរអន្តរជាតិរបស់កម្ពុជា និងជឿជាក់ថា ភ្ញៀវទេសចរអន្តរជាតិនឹងមកកម្សាន្តប្រទេសកម្ពុជាកាន់តែច្រើន តាមរយៈការជួយផ្សព្វផ្សាយរបស់អង្គការទេសចរណ៍ពិភពលោកនេះ។ *ដោយ ម៉ែន ខេមរៈ*

*ប្រភព ៖ freshnews ចេញផ្សាយថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០២១។*

## តម្លៃស្រូវធ្លាក់ចុះនៅឆ្នាំនេះ ធ្វើឱ្យកសិករខេត្តស្វាយរៀងមិនសូវចំណេញ



*ដោយ freshnews (ស្វាយរៀង)*

ប្រជាកសិករនៅភូមិស្វាយតាភ្លូ ឃុំបាសាក់ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង បានឱ្យដឹងថា ទិន្នផលស្រូវនៅឆ្នាំនេះ ពុំសូវទទួលបានផលដូចឆ្នាំមុនៗទេព្រោះស្មៅដុះច្រើនក្នុងស្រែ។ ចំពោះតម្លៃស្រូវវិញធ្លាក់ចុះទៀត អ្នកខ្លះបានស្មើដើម អ្នកខ្លះខាតបង់ អ្នកខ្លះបានចំណេញខ្លះ បើធៀបទៅនឹងការចំណាយទៅលើដី ប្រេង និងថ្នាំដែលទិញពីវៀតណាម។ ការធ្វើស្រូវប្រាំងក៏ដូចជាស្រូវវស្សាតែងតែទៅបន្ទាក់ជីគីមី ប្រេង ថ្នាំសម្លាប់សត្វល្អិតពីអាជីវករវៀតណាម លុះដល់ពេលប្រមូលផលស្រូវទើបទូទាត់សងគេវិញ។ ដល់រដូវច្រូតកាត់ឈ្មួញវៀតណាម តែងតែមកទិញស្រូវពីខ្មែរនៅព្រំដែន ហើយកំណត់តម្លៃស្រូវតាមតែចិត្ត នេះគឺដោយសារយើងគ្មានទីផ្សារក្នុងស្រុក។ ប្រជាកសិករ

បានស្នើដល់អាជ្ញាធរជួយទិញស្រូវដើម្បីកុំឱ្យឈ្មួញវៀតណាមផ្តាច់មុខពេក។ ក្នុងនោះដែរក៏បានស្នើសុំជួយប្រឡាយទឹកនៅភូមិស្វាយតាភ្លួ ឃុំបាសាក់ ស្រុកស្វាយជ្រំ ដើម្បីប្រើប្រាស់ ព្រោះសព្វថ្ងៃពួកគាត់បានជីកអណ្តូងដើម្បីធ្វើស្រែប្រាំង ហើយទិញទឹកពីវៀតណាមយកមកប្រើប្រាស់ផងដែរ។

ខេត្តស្វាយរៀង មានច្រកអន្តរជាតិព្រៃវល្លិស្ថិតនៅក្នុងស្រុកកំពង់រោទិ៍ ដឹកជញ្ជូនស្រូវ តាមប្រឡាយទាហានស្ថិតក្នុងឃុំថ្មីទៅលក់នៅប្រទេសវៀតណាម ក្នុងមួយថ្ងៃមានរថយន្តប្រមាណជាង ១ពាន់ គ្រឿង និងមានកាណូតឈ្មួញវៀតណាម ឡើងមកទិញដល់ទឹកដីខ្មែរ។ ក្រុមអាជីករខ្មែរបានទិញស្រូវរបស់ប្រជាពលរដ្ឋ ពីខេត្តព្រៃវែង ពោធិ៍សាត់ កំពង់ធំ និងខេត្តមួយចំនួនទៀតមកលក់នៅច្រកនេះ។ ដោយសារច្រកអន្តរជាតិបន្ទាយចក្រី ស្រុកព្រះស្តេច ខេត្តព្រៃវែង ត្រូវបានភាគីវៀតណាមមិនឱ្យដឹកស្រូវចូលលក់ក្នុងទឹកដីរបស់គេ ដោយអះអាងថា ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជម្ងឺកូវីដ១៩ ទើបក្រុមអាជីវករខ្មែរ បានសម្រុកនាំស្រូវទៅលក់នៅច្រកទ្វារអន្តរជាតិព្រៃវល្លិ៍ ខេត្តស្វាយរៀងយ៉ាងគគ្រឹកគគ្រេងតែម្តង៕ ដោយ ម៉ែន ខេមរៈ

*ប្រភព ៖ freshnews ចេញផ្សាយថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១។*

## កត្តាចម្បង៤ ធ្វើឱ្យសហគ្រិនក្នុងវិស័យស្វាយចន្ទី នៅខេត្តត្បូងឃ្មុំ ទទួលបានជោគជ័យ



*ដោយ Freshnews*

លេខាធិការដ្ឋានមូលនិធិអភិវឌ្ឍន៍សហគ្រិនភាពនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានធ្វើការសិក្សាលើផលិតផលកសិកម្មដែលមានសក្តានុពលចំនួន១០ រួមមាន៖ ស្វាយចន្ទី, ធុរេន, មៀន, ក្រូច, ស្រកានាគ, ម្រេច, ដូង, សូត្រ, សំបុកត្រចៀកកាំ និងទឹកឃ្មុំ។ ជាលទ្ធផលបានពិនិត្យឃើញថា គ្រាប់ស្វាយចន្ទី មានសក្តានុពលជាងគេសម្រាប់នាំចេញព្រោះកំណើននៃបរិមាណ ទិន្នផល តម្លៃ និងមានតម្រូវការខ្ពស់នៅបរទេស ពិសេសប្រទេសចិន។

នៅក្នុងខេត្តត្បូងឃ្មុំ មានក្រុមហ៊ុន MTST Agro Product Co., Ltd មានរោងចក្រកែច្នៃគ្រាប់ស្វាយចន្ទីដែលបាននិងកំពុងនាំចេញទៅកាន់ប្រទេសថៃ, ម៉ាឡេស៊ី, ទីក្រុងហុងកុង និងវៀតណាមជាដើម។ ប្រធានលេខាធិការដ្ឋានមូលនិធិអភិវឌ្ឍន៍សហគ្រិនភាព បានដឹកនាំក្រុមការងារចុះសិក្សាស្រាវជ្រាវ នៅរោងចក្រនោះក្នុងគោលបំណងសិក្សាពីបទពិសោធន៍ជោគជ័យលើការនាំចេញគ្រាប់ស្វាយចន្ទី ដើម្បីចងក្រងទិន្នន័យធ្វើជាមូលដ្ឋានក្នុងការរៀបចំកម្មវិធីអភិវឌ្ឍន៍សមត្ថភាពសហគ្រិនផ្សេងទៀត លើដំណាំស្វាយចន្ទី សំដៅចូលរួមពង្រីកផលិតភាពកែច្នៃ។ ដំបូងម្ចាស់ក្រុមហ៊ុន MTST Agro Product Co., Ltd បានលក់គ្រាប់ស្វាយចន្ទី មិនទាន់កែច្នៃទៅឱ្យឈ្មួញវៀតណាម ប៉ុន្តែបន្ទាប់ពីបានទទួលឱកាសសហការជាមួយរោងចក្រមួយនៅប្រទេសវៀតណាម លោកក៏បានទទួលបានបទពិសោធន៍ក្នុងការច្នៃ និងបានកសាងបណ្តាញអាជីវកម្មបានយ៉ាងល្អ ហើយលោក រៀបចំឱ្យមានរោងចក្រផ្ទាល់ខ្លួនតែម្តងនៅខេត្តត្បូងឃ្មុំនេះ។ ដោយមើលឃើញពីសក្តានុពលខ្ពស់នៃដំណាំស្វាយចន្ទីកម្ពុជា លោកមានបំណងចង់ពង្រីកខ្សែសង្វាក់ផលិតកម្មឱ្យកាន់តែធំបន្ថែមទៀត ដើម្បីកែច្នៃរហូតដល់ ២០០ ០០០តោននៃគ្រាប់ស្វាយចន្ទីស្រស់ក្នុងមួយឆ្នាំ និងជាពិសេសចង់

ទទួលបានវិញ្ញាបនបត្រ ISO ជាដើម នាពេលខាងមុខនេះ។

លោកប្រធានបានបញ្ជាក់ថា កត្តាចម្បងចំនួន០៤ ដែលនាំឱ្យទទួលបានជោគជ័យកន្លងមក មាន ៖ ការកសាងបណ្តាញអាជីវកម្ម ជំនាញបច្ចេកទេស ការលក់ផលិតផលសំណល់ពីការកែច្នៃ និងចំណេះដឹងច្បាស់លាស់អំពីខ្សែសង្វាក់ផលិតកម្ម។

លោកក៏បានស្នើសុំរាជរដ្ឋាភិបាលជួយ សម្របសម្រួលការវិនិយោគឱ្យមានកន្លែងប្រមូលផ្តុំ ដូចជាការបង្កើតសួនកសិ-ឧស្សាហកម្ម ដែលមានការរៀបចំហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ជាលក្ខណៈប្រព័ន្ធអេកូឡូស៊ី និងទាក់ទាញវិនិយោគគិន ដែលមានជំនាញ និងបទពិសោធន៍ពាក់ព័ន្ធនឹងការបង្កើតរោងចក្រមានស្តង់ដារ, ឃ្លាំងស្តុកសុវត្ថិភាព, ប្រព័ន្ធគ្រប់គ្រងមានប្រសិទ្ធភាព, ការបណ្តុះបណ្តាលជំនាញត្រឹមត្រូវ និងការប្រើប្រាស់បច្ចេកវិទ្យាទំនើបនៅក្នុងខ្សែច្រវាក់ផលិតកម្មជាដើម ដើម្បីអាចជួយពង្រីកផលិតកម្មកែច្នៃសម្រាប់បង្កើនការនាំចេញកាន់តែច្រើនជាងមុន៕ *ដោយ ម៉ែន ខែមរៈ*

*<u>ប្រភព៖Freshnews ចេញផ្សាយថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១។</u>*

## តារាងប្រចាំសប្តាហ៍

### តារាងទី១៖ តារាងប្រៀបធៀបប្រាក់បញ្ញើនៅធនាគារទទួលប្រាក់បញ្ញើ ប្រចាំខែកក្កដា ឆ្នាំ២០២១

| គិតជាប៊ីលានរៀល | កក្កដា-២០ | កក្កដា-២១ | កំណើន |
|---|---|---|---|
| សរុបប្រាក់បញ្ញើជាប្រាក់រៀល | 8,809.5 | 12,325.6 | 39.91% |
| សរុបប្រាក់បញ្ញើជារូបិយប័ណ្ណ | 101,214.8 | 117,907.0 | 16.49% |
| **សរុបប្រាក់បញ្ញើ** | 110,024.3 | 130,232.6 | 18.37% |
| សរុបប្រាក់បញ្ញើជាប្រាក់រៀល/សរុប | 8.0% | 9.5% | |
| សរុបប្រាក់បញ្ញើជារូបិយប័ណ្ណ/សរុប | 92.0% | 90.5% | |

តារាងទី១៖ ខាងលើនេះបានបង្ហាញ ពីការប្រៀបធៀបការដាក់ប្រាក់បញ្ញើនៅធនាគារទទួលប្រាក់បញ្ញើ ក្នុងខែកក្កដា ឆ្នាំ២០២១ ដែលមានកំណើន ១៨% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០។ ក្នុងនោះ សរុបប្រាក់បញ្ញើជាប្រាក់រៀល មានចំនួនប្រហែល ១២ ៣២៦ ប៊ីលានរៀល ដែលកើនឡើងជិត៤០% ពី ៨ ៨១០ ប៊ីលានរៀល ក្នុងរយៈពេលដូចគ្នាឆ្នាំ២០២០។ ប្រាក់បញ្ញើសរុបជារូបិយប័ណ្ណកើនឡើង១៦% ដែលមានចំនួន ១១៧ ៩០៧ ប៊ីលានរៀល ពី១១០ ០២៤ ប៊ីលានរៀល ក្នុងរយៈពេលដូចក្នុងឆ្នាំ២០២០។

សរុបប្រាក់បញ្ញើជាប្រាក់រៀល ធៀបនឹងប្រាក់បញ្ញើសរុបមានចំនួន ៩,៥% ក្នុងខែកក្កដា ឆ្នាំ២០២១ ដែលបានកើនឡើងពី ៨%ក្នុងរយៈពេលដូចគ្នាឆ្នាំ២០២០។ ប្រាក់បញ្ញើសរុបជារូបិយប័ណ្ណធៀបនឹងប្រាក់បញ្ញើសរុបដែលមានចំនួន៩០,៥% កើនឡើងពី ៩២% ក្នុងរយៈពេលដូចគ្នាឆ្នាំ២០២០៕ *ដោយ ឈន ហាំ*

*<u>ប្រភព៖ ធនាគារជាតិនៃកម្ពុជា ចុះនាថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០ និង ចុះនាថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១</u>*

### ក្រាហ្វស្ថិតិទី១៖ ប្រាក់បញ្ញើជាប្រាក់រៀលចំណាត់ថ្នាក់តាមប្រភេទ ក្នុងខែកក្កដា ឆ្នាំ២០២១(គិតជាភាគរយនៃប្រាក់បញ្ញើជាប្រាក់រៀលសរុប)




*ប្រភព៖ ធនាគារជាតិនៃកម្ពុជា*

ក្រាហ្វស្ថិទី១ ៖ ខាងលើនេះបង្ហាញ ប្រាក់បញ្ញើជាប្រាក់រៀលចំណាក់ថ្នាក់តាមប្រភេទ ក្នុងខែកក្កដា ឆ្នាំ២០២១ ដែលមានដូចជា៖ ប្រាក់បញ្ញើសន្សំដែល មានចំនួន (២២,៣០%),ប្រាក់បញ្ញើមានកាលកំណត់(៤៥%), ប្រាក់បញ្ញើចរន្ត(៣១,១០%) និងផ្សេងៗ(១,៤០%)៕

*ដោយ ឈន ហាំ*

*ប្រភព៖ធនាគារជាតិនៃកម្ពុជា ចុះនាថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១*

**ក្រាហ្វស្ថិតិទី១៖ ប្រាក់បញ្ញើជារូបិប័ណ្ណចំណាត់ថ្នាក់តាមប្រភេទ ក្នុងខែកក្កដា ឆ្នាំ២០២១(គិតជាភាគរយនៃប្រាក់បញ្ញើជារូបិប័ណ្ណសរុប)**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ក្រាហ្វស្ថិទី១៖ ខាងលើនេះបង្ហាញ ប្រាក់បញ្ញើជារូបិប័ណ្ណចំណាក់ថ្នាក់តាមប្រភេទ ក្នុងខែកក្កដា ឆ្នាំ២០២១ ដែលមានដូចជា៖ ប្រាក់បញ្ញើសន្សំមានចំនួន(៣១,៤០%), ប្រាក់បញ្ញើមានកាលកំណត់(៤៥,៦០%),ប្រាក់បញ្ញើចរន្ត(២១,៧០%) និងផ្សេងៗ(១,៤០%)៕

*ដោយ ឈន ហាំ*

*ប្រភព៖ធនាគារជាតិនៃកម្ពុជា ចុះនាថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១*

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ចិនគ្រោងទិញកសិផលពីតំបន់អាស៊ានទ្វេដងក្នុងទឹកប្រាក់១៥០ពាន់លានដុល្លារនៅ៥ឆ្នាំខាងមុខ




*ដោយ ខេមបុណ្ណមីស*

នៅក្នុងអំឡុងកិច្ចប្រជុំកំពូលពិសេសអាស៊ាន-ចិន កំពូលមេដឹកនាំរដ្ឋចិន បានបញ្ជាក់ពីគោលបំណងមួយចង់បង្កើនការបញ្ជាទិញផលិតផលកសិកម្មពីតំបន់អាស៊ានទ្វេដង ដែលមានទំហំទឹកប្រាក់ប្រមាណ ១៥០ ពាន់លានដុល្លារអាមេរិក ក្នុងរយៈពេល៥ឆ្នាំខាងមុខ។ នេះវាជាការបង្ហាញពីការប្តេជ្ញាចិត្តរបស់ចិនក្នុងការជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគី និងជួយស្តារសេដ្ឋកិច្ចក្នុងតំបន់មួយនេះ ក្រោយជំងឺរាតត្បាតកូវីដ១៩។ នៅឆ្នាំ២០១៨ ទំហំការនាំចូលកសិផលពីអាស៊ានទៅចិនមានត្រឹមតែជាង១៨ពាន់លានដុល្លារប៉ុណ្ណោះ។ ពាណិជ្ជកម្មលើកសិផលរវាងភាគីទាំងពីរ កំពុងពង្រីកវិសាលភាពកាន់តែធំទៅៗ នៅប៉ុន្មានឆ្នាំចុងក្រោយនេះ។ ពីមុនមកចិននាំចូលពីអាស៊ានតែផលិតផលផ្លែឈើប៉ុណ្ណោះ ប៉ុន្តែអំឡុងពេលមានជម្លោះពាណិជ្ជកម្មជាមួយសហរដ្ឋអាមេរិកប្រទេសចិនបានបង្កើនការនាំចូលអង្ករ និងសណ្តែកសៀងបន្ថែមទៀត។ ក្នុងចំណោមសមាជិកអាស៊ានទាំង១០ប្រទេស ប្រទេសថៃ

និង ឥណ្ឌូនេស៊ីជាប្រភពនាំចូលកសិផលរបស់ចិនធំជាងគេ។

សូមជម្រាបថា បើតាមទិន្នន័យពីរដ្ឋបាលគយរបស់ចិន ពាណិជ្ជកម្មបន្លែផ្លែឈើរវាងចិន និងអាស៊ានកាលពីឆ្នាំ២០២០ មានជាង ១៥ពាន់លានដុល្លារអាមេរិក។ ក្នុងនោះការនាំចេញផ្លែឈើពីអាស៊ានទៅចិន មានតម្លៃជាង៦ពាន់លានដុល្លារ។ ដោយឡែក គ្រាន់តែនៅ៨ខែឆ្នាំ២០២១នេះ ពាណិជ្ជកម្មបន្លែនិងផ្លែឈើរវាងចិន និងអាស៊ាន បានកើនឡើងលើសតួលេខពេញមួយឆ្នាំ២០២០ រួចទៅហើយ ពោលគឺអាស៊ានបាននាំចេញផ្លែឈើទៅចិន កើនលើស ៦,៤ពាន់លានដុល្លារអាមេរិក៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១។*

## អតិរេកពាណិជ្ជកម្មរបស់ឥណ្ឌូនេស៊ី សម្រាប់ខែតុលា ឆ្នាំ២០២១ (គិតជាពាន់លានដុល្លារ)

ការនាំចេញទំនិញសរុបរបស់ប្រទេសឥណ្ឌូនេស៊ីមានចំនួន ២២,០៣ ពាន់លានដុល្លារ នៅក្នុងខែតុលា ឆ្នាំ២០២១ ធៀបទៅនឹងខែរយៈពេលដូចគ្នាកាលពីឆ្នាំមុន បានកើនឡើង៥៣,៣៥%។ ការនាំចេញ ដែលមានទំហំធំបំផុត គឺផលិតផលមិនមែនប្រេង និងឧស្ម័ន ដែលបានរួមចំណែក ២១ ពាន់លានដុល្លារ ក្នុងនោះនាំចេញទៅចិនមានចំនួន ៥,៩៣ ពាន់លានដុល្លារ សហរដ្ឋអាមេរិកមានចំនួន ២,៣៤ ពាន់លានដុល្លារ និងជប៉ុនមានចំនួន ១,៤១ ពាន់លានដុល្លារ ស្មើនឹង ៤៦,១០% ខណៈការនាំចេញទៅកាន់អាស៊ាន និងសហគមន៍អឺរ៉ុបមានចំនួន ៣,៥៥ ពាន់លានដុល្លារ និង ១,៥៤ ពាន់លានដុល្លារអាមេរិក រៀងគ្នា។

រីឯ ការនាំចូលសរុបមានទំហំ ១៦,២៩ ពាន់លានដុល្លារ នៅក្នុងខែតុលា ឆ្នាំ២០២១ បើធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន បានកើនឡើង ៥១,០៦%។ ការនាំចូលភាគច្រើន គឺផលិតផលមិនមែនប្រេង និងឧស្ម័ន ដែលមាន ១៤,៣៩ ពាន់លានដុល្លារ បើធៀបទៅនឹងខែរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០ បានកើនឡើង ៤៨,២៩%។

ជារួម ប្រទេសឥណ្ឌូនេស៊ីនៅតែមានអតិរេកពាណិជ្ជកម្ម ៥,៧៣ ពាន់លានដុល្លារអាមេរិក នៅក្នុងខែតុលា ឆ្នាំ២០២១៕ *ដោយ ជឹម ប៊ុនជឿន*

| | ទំហំជួញដូរ |
|---|---|
| ការនាំចូល | ២២,០៣ |
| ការនាំចេញ | ១៦,២៩ |
| តុល្យភាពពាណិជ្ជកម្ម | ៥,៧៣ |

*ប្រភព៖ bps*

## ពាណិជ្ជកម្មវៀតណាម សម្រាប់ពាក់កណ្តាលខែចុងក្រោយ នៃខែកញ្ញា ឆ្នាំ២០២១ (គិតជាពាន់លានដុល្លារ)

យោងតាមស្ថិតិគយប្រទេសវៀតណាមបានបង្ហាញថា ការនាំចេញសរុបរបស់ប្រទេសវៀតណាម មានចំនួន ១៥,៤៧ ពាន់លានដុល្លារ ខណៈការនាំចូលមានចំនួន ១៣,៦ ពាន់លានដុល្លារ។ ដូច្នេះ វៀតណាម មានអតិរេកពាណិជ្ជកម្មចំនួន ១,៨៧ ពាន់លានដុល្លារ សម្រាប់រយៈពេលពាក់កណ្តាលខែចុងក្រោយ នៃខែកញ្ញា ឆ្នាំ២០២១។

បើធៀបទៅនឹងពាក់កណ្តាលខែដំបូង នៃខែកញ្ញា ឆ្នាំ២០២១ ការនាំចេញបានកើនឡើង ៣៣,៧%។ កំណើននៃការនាំចេញនោះ រួមមានការកើនឡើងនៃទូរស័ព្ទ ទូរស័ព្ទដៃ និងគ្រឿងបន្លាស់របស់វាមាន ៣៩,៣% ស្មើនឹង ៩៣៥ លានដុល្លារ កុំព្យូទ័រ ផលិតផលអគ្គិសនីមាន ៤១,១% ស្មើនឹង ៨១៣ លានដុល្លារ ដែក និងដែកថែបមាន ៨៦,៦% ស្មើនឹង ៤២៦ លានដុល្លា ម៉ាស៊ីន ឧបករណ៍ និងគ្រឿងបរិក្ខាមាន ២១,៩% ស្មើនឹង២៩២ លានដុល្លា។

រីឯ ការនាំចូលបានកើនឡើង ៤% ធៀបទៅនឹងពាក់កណ្តាលខែដំបូង នៃខែកញ្ញា ឆ្នាំ២០២១ ដែលឆ្លុះបញ្ចាំងពីការកើនឡើងនៃការនាំចូលកុំព្យូទ័រ និងផលិតផលអគ្គិសនីមាន ១២,២% ស្មើនឹង ៣៩៧លានដុល្លារ ទូរស័ព្ទ ទូរស័ព្ទដៃ និងគ្រឿងគ្រឿងបន្លាស់មាន ២៦,៤% ស្មើនឹង ២៥៨ លានដុល្លារ និងម៉ូតូមាន ៩៤,៨% ស្មើនឹង ៦៤ លានដុល្លារ៕

*ដោយ ជឹម ប៊ុនធឿន*

| | ទំហំជួញដូរ |
|---|---|
| ការនាំចូល | ១៥,៤៧ |
| ការនាំចេញ | ១៣,៦ |
| តុល្យភាពពាណិជ្ជកម្ម | ១,៨៧ |

*ប្រភព៖ Vietnam Customs*

## អត្រាភាពគ្មានការងារធ្វើរបស់ប្រទេសថៃឈានដល់២,២៥%នៅក្នុងត្រីមាសទី៣




| Components | Year 2019 | Year 2020 | 2019 Q1 | 2019 Q2 | 2019 Q3 | 2019 Q4 | 2020 Q1 | 2020 Q2 | 2020 Q3 | 2020 Q4 | 2021 Q1 | 2021 Q2 | 2021 Q3 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **Employment*** | | | | | | | | | | | | | |
| Workforce (million) | 38.17 | 38.54 | 38.36 | 38.42 | 37.95 | 37.96 | 38.19 | 38.17 | 38.72 | 39.08 | 38.75 | 38.77 | 38.64 |
| % year-on-year | 0.7 | 1.0 | 0.6 | -0.2 | -2.0 | -1.1 | -0.4 | -0.6 | 2.0 | 2.9 | 1.5 | 1.6 | -0.2 |
| Employed (million) | 37.61 | 37.68 | 37.70 | 37.78 | 37.48 | 37.48 | 37.42 | 37.08 | 37.92 | 38.28 | 37.58 | 37.82 | 37.70 |
| % year-on-year | -0.7 | 0.2 | 0.9 | -0.3 | -2.1 | -1.1 - | 0.7 | -1.9 | 1.2 | 2.2 | 0.4 | 2.0 | -0.6 |
| Unemployed | 373,000 | 651,000 | 351,000 | 377,000 | 394,000 | 372,000 | 395,000 | 745,000 | 738,000 | 727,000 | 758,000 | 732,000 | 871,000 |
| Unemployment rate (%) | 0.98 | 1.69 | 0.92 | 0.98 | 1.04 | 0.98 | 1.03 | 1.95 | 1.90 | 1.86 | 1.96 | 1.89 | 2.25 |
| **Household debt**** | | | | | | | | | | | | | |
| Household debt value (trillion baht) | 13.49 | 14.03 | 12.97 | 13.09 | 13.25 | 13.49 | 13.50 | 13.59 | 13.77 | 14.03 | 14.14 | 14.27 | N.A. |
| % year-on-year | 5.1 | 4.0 | 6.3 | 5.8 | 5.6 | 5.1 | 4.1 | 3.8 | 3.9 | 4.0 | 4.7 | 5.0 | N.A |
| Ratio to GDP (%) | 79.8 | 89.4 | 78.4 | 78.4 | 78.8 | 79.8 | 80.2 | 83.8 | 86.6 | 89.4 | 90.6 | 89.3 | N.A |
| NPLs (billion baht) | 140.6 | 144.4 | 126.4 | 127.4 | 133.3 | 140.6 | 156.2 | 152.5 | 144.3 | 144.4 | 148.7 | 150.4 | N.A. |
| % year-on-year | 16.7 | 2.7 | 9.0 | 10.0 | 12.2 | 16.7 | 23.6 | 19.7 | 8.3 | 2.7 | -4.8 | -1.4 | N.A |
| % NPLs to total loans | 2.90 | 2.84 | 2.75 | 2.74 | 2.81 | 2.90 | 3.23 | 3.12 | 2.91 | 2.84 | 2.92 | 2.92 | N.A. |

Source: *Source: Labor force survey report, National Statistical Office, Ministry of Digital Economy and Society
** Bank of Thailand
BANGKOK POST GRAPHICS

*ប្រភព៖ bangkokpost, 2021*

ទីផ្សារការងាររបស់ប្រទេសថៃត្រូវបានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយការដាក់ចេញនូវវិធានការតឹងរ៉ឹងរបស់រាជរដ្ឋាភិបាលដើម្បីគ្រប់គ្រងការរីករាលដាលនៃជំងឺកូវីដ-១៩ ជាមួយនឹងអត្រាគ្មានការងារធ្វើកើនឡើងដល់ ២,២៥% នៅក្នុងត្រីមាសទី ៣ ដែលកើនឡើង ពី ១,៨៩% ក្នុងបីខែមុន ខណៈដែលបំណុលគ្រួសារនៅតែបន្តកើនឡើង។

អង្គភាពផែនការរបស់រដ្ឋាភិបាល ,ក្រុមប្រឹក្សាអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមជាតិ (NESDC) បានរាយការណ៍ថា មនុស្សសរុបចំនួន ៨៧១ ០០០នាក់បានអត់ការងារធ្វើនៅក្នុងត្រីមាសទី ៣ ពោលគឺកើនឡើងពី ៧៣២ ០០០នាក់នៅក្នុងត្រីមាសទី២។

អត្រាគ្មានការងារធ្វើសម្រាប់អ្នកដែលមានការអប់រំខ្ពស់គឺខ្ពស់បំផុត ៣,៦៣% ,បន្ទាប់មកអ្នកកាន់សញ្ញាបត្រវិជ្ជាជីវៈ ៣,១៦%។

នៅក្នុងត្រីមាសទី ៣ មានបុគ្គលិកចំនួន ៣៧,៧លាននាក់ ធ្លាក់ចុះ ០,៦% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ការងារនៅក្នុងវិស័យកសិកម្មបានកើនឡើងដោយមានប្រជាជនចំនួន ១២,៦៨ លាននាក់ កើនឡើង ១% ដោយសាររដូវដាំដុះស្រូវចាប់ផ្តើម។ ការងារមិនមែនកសិកម្មបានធ្លាក់ចុះ ១,៣%ក្នុងនោះវិស័យសំណង់បាត់បង់ការងារច្រើនជាងគេបន្ទាប់មកគឺវិស័យសណ្ឋាគារ/ភោជនីយដ្ឋាន ដែលធ្លាក់ចុះ ៧,៣% និង ៩,៣% រៀងគ្នា ការធ្លាក់ចុះនេះគឺដោយសារវិធានការគ្រប់គ្រងការបើក និងបិទសហគ្រាស ក៏ដូចជាការបិទជំរុំកម្មករ និងការលក់អាហារមានកំណត់។ ទន្ទឹមនឹងនេះ ការងារក្នុងវិស័យ ផលិតកម្ម ការលក់ដុំ/លក់រាយ និងការដឹកជញ្ជូន/ការផ្ទុកទំនិញបានកើនឡើង ២,១%, ០,២% និង ៤,៦% រៀងគ្នា។ វិស័យផលិតកម្មដែលបានឃើញពីកំណើនការងាររួមមាន៖ ផលិតកម្មអាហារ និងភេសជ្ជៈ ការផលិតរថយន្ត គ្រឿងបរិក្ខាអគ្គិសនី និងការផលិតឧបករណ៍វេជ្ជសាស្ត្រ។

សម្រាប់ម៉ោងធ្វើការជាមធ្យមក្នុងវិស័យឯកជនគឺ ៤៣,៩ ម៉ោងក្នុងមួយសប្តាហ៍ ធ្លាក់ចុះពី ៤៤ម៉ោងក្នុងមួយសប្តាហ៍ក្នុងអំឡុងពេលដូចគ្នាកាលពីឆ្នាំមុន។ លោក

Danucha បានមានប្រសាសន៍ថា អត្រាការងារនៅក្នុងត្រីមាសទី៤ទំនងជាមានភាពប្រសើរឡើងដោយសារតែការបើកប្រទេសឡើងវិញនៅថ្ងៃទី១ខែវិច្ឆិកា។ ទោះបីជាយ៉ាងណាក៏ដោយ លោកបានកត់សម្គាល់ថា ការព្យាករណ៍នេះគឺផ្អែកលើអវត្តមាននៃការកើតឡើងវិញនៃការឆ្លងមេរោគ កូវីដ-១៩ ។ NESDC បានបង្ហាញផងដែរថាបំណុលគ្រួសារមានចំនួន ១៤,២៧ ទ្រីលានបាតក្នុងត្រីមាសទីពីរកើនឡើង៥% ពី ១៤,៤ ទ្រីលានបាតក្នុងត្រីមាសមុន។ តួលេខនេះសមាមាត្រនឹង៨៩,៣% នៃ ផ.ស.ស ធ្លាក់ចុះពី ៩០,៦% ក្នុងត្រីមាសមុន។បើទោះបីជាសមាមាត្រប្រាក់កម្ចីមិនដំណើរការ (NPL) នៃប្រាក់កម្ចីអតិថិជនមាន ២,៩២% មិនផ្លាស់ប្តូរពីត្រីមាសមុនក៏ដោយ អនុបាត NPL នៃប្រាក់កម្ចីកាតឥណទានបានកើនឡើងសម្រាប់ត្រីមាសទីពីរជាប់ៗគ្នាពី ៣,០៤% ទៅ ៣,៥១% បំណុលគ្រួសារទាំងមូលនឹងកើនឡើងដោយសារតែស្ថានភាពសេដ្ឋកិច្ចមិនស្ថិតស្ថេរ ហើយរំពឹងថាបំណុលនឹងកើនឡើងដោយសារផលប៉ះពាល់នៃទឹកជំនន់ ជាហេតុនាំឱ្យប្រជាជនត្រូវជួសជុលផ្ទះ និងសម្ភារៈប្រើប្រាស់ដែលរងការខូចខាត៕

*ដោយ សេន ចន្ទី*

*ប្រភព៖bangkokpost.ចេញផ្សាយថ្ងៃទី២៣ខែវិច្ឆិកា ឆ្នាំ២០២១*

## ប្រទេសថៃនឹងប្រឈមហានិភ័យផ្នែកសេដ្ឋកិច្ច ក្រោមការផ្លាស់ប្តូរទិដ្ឋភាពសេដ្ឋកិច្ចទូទាំងពិភពលោក



*ដោយ ខេមបូណ្ឌមីស*

ធនាគារបាងកក(BBL)ព្យាករណ៍ថា សេដ្ឋកិច្ចថៃប្រឈមមុខនឹងបញ្ហាកាន់តែច្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះក្រោមការផ្លាស់ប្តូរទិដ្ឋភាពសេដ្ឋកិច្ចទូទាំងពិភពលោក គឺការប្រកួតប្រជែងកាន់តែខ្លាំងជាសកល និងការរំខានផ្នែកបច្ចេកវិទ្យាឌីជីថល ភាពតានតឹងរវាងសង្គ្រាមពាណិជ្ជកម្មរដ្ឋអាមេរិក-ចិន និងការផ្លាស់ប្តូរភូមិសាស្ត្រនយោបាយនៅអាស៊ីជាដើម បើទោះបីជា សេដ្ឋកិច្ចថៃនឹងងើបឡើងវិញជាបណ្តើរៗចាប់ពីនៅឆ្នាំ២០២២ដោយការបើកប្រទេសឡើងវិញក្តី។ ចំពេលជាមួយគ្នានេះ អាជីវកម្មនានាក៏អាចទទួលបានឱកាសថ្មី ដើម្បីរៀបចំសម្រាប់ការចាប់ផ្តើមអាជីវកម្មឡើងវិញបន្ទាប់ពីជំងឺរាតត្បាតផងដែរ។ ឱកាសទាំងនោះរួមមាន ការអភិវឌ្ឍន៍ឌីជីថល ការកែលម្អអាជីវកម្ម និងការផលិតជាដើម។ សន្ទុះសេដ្ឋកិច្ចរបស់ប្រទេសថៃក៏នឹងពឹងផ្អែកលើវិស័យទេសចរណ៍ ដោយចាប់ពីពាក់កណ្តាលឆ្នាំក្រោយ ប្រទេសថៃត្រូវបានគេរំពឹងថា នឹងស្វាគមន៍ភ្ញៀវទេសចរអន្តរជាតិប្រហែល ៥០% នៃចំនួនសរុប ដែលធ្លាប់បានកត់ត្រានៅមុនពេលមានជំងឺរាតត្បាត ហើយចំនួននេះនឹងបន្តកើនឡើងដល់ ៨០% នៅត្រឹមឆ្នាំ ២០២៣។

តាមការព្យាករចុងក្រោយរបស់ក្រសួងហិរញ្ញវត្ថុថៃបានឱ្យដឹងថា កំណើនសេដ្ឋកិច្ចថៃ នៅឆ្នាំ២០២១នេះ រំពឹងនឹងកើនឡើងជាង១% បន្ទាប់ពីបានធ្លាក់ចុះជាង៦% កាលពីឆ្នាំ២០២០ ហើយសម្រាប់ឆ្នាំ២០២២វិញ រំពឹងនឹងបន្តកើនឡើងចន្លោះពី ៣,៥% ទៅ៤,៥% ដោយសារតែការនាំចេញកើនឡើង និងការងើបឡើងវិញនៃវិស័យទេសចរណ៍៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១។*

## រាជរដ្ឋាភិបាលនៃប្រទេសឡាវគ្រោងនឹងចំណាយថវិកាជាង ១០០លានដុល្លារដើម្បីជំរុញផលិតកម្មក្នុងស្រុក



*ប្រភព៖laotiantimes , 2021 រូបភាព៖ ILO*

រដ្ឋាភិបាលនៃប្រទេសឡាវគ្រោងចំណាយថវិកាជាង ១០០លានដុល្លារដើម្បីជំរុញផលិតកម្មក្នុងស្រុក និងជំរុញការនាំចេញ។ យោងតាម ភ្នាក់ងារសារព័ត៌មានបន្ទាប់របស់ប្រទេសឡាវ(KPL) បានឱ្យដឹងថា ប្រាក់កម្ចីពីធនាគារអភិវឌ្ឍន៍ជាតិរបស់របស់ប្រទេសចិន (CDB) នឹងត្រូវបានប្រើដើម្បីផ្តល់មូលនិធិដល់សហគ្រាសដែលជ្រើសរើសចំពេលមានការខិតខំប្រឹងប្រែងរបស់រដ្ឋា ភិបាលក្នុងការបង្កើនផលិតកម្មក្នុងស្រុក និងការនាំចេញទៅកាន់បរទេស។ ទេសាភិបាលធនាគារកណ្តាលឡាវ លោក Sonexay Sitphaxay បានមានប្រសាសន៍ក្នុងសម័យប្រជុំរដ្ឋសភាកាលពីពេលថ្មីៗនេះថា សេដ្ឋកិច្ចឡាវស្ថិតនៅក្រោមសម្ពាធយ៉ាងខ្លាំង ដោយសារការឡើងថ្លៃរូបិយប័ណ្ណបរទេសដ៏សំខាន់ ថ្លៃដើមប្រេងឆៅកើនឡើង ធ្វើឱ្យមានអតិផរណា និងអត្រាការប្រាក់អន្តរជាតិ។ ទន្ទឹមនឹងនេះលោកបានបន្តទៀតថារដ្ឋាភិបាលនឹងប្រើប្រាស់មូលនិធិពីធនាគារអភិវឌ្ឍន៍ជាតិរបស់ប្រទេសចិន(CDB)ដោយរំពឹងថាថវិកា១០០ លានដុល្លារគឺជាលើកដំបូងក្នុងការបង់រំលោះរហូតដល់ខែមីនា ឆ្នាំ២០២២។ រដ្ឋាភិបាលក៏នឹងទទួលបានមូលនិធិពីធនាគារពិភពលោក ក៏ដូចជាមូលនិធិហិរញ្ញវត្ថុឡាវ(LAFF) និងប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជដែលត្រូវបានរំពឹងថានឹងកើនឡើងបន្ទាប់ពីការចាប់ផ្តើមគម្រោងផ្លូវដែកឡាវ-ចិន។

រដ្ឋាភិបាលនឹងផ្តល់គោលនយោបាយហិរញ្ញវត្ថុមួយចំនួនសម្រាប់គម្រោងអាជីវកម្មខ្នាតតូច និងសហគ្រាសធុនតូចនិងមធ្យម(SMEs)។ អាជ្ញាធរនឹងសម្របសម្រួលរវាងវិស័យសាធារណៈនិងឯកជនដើម្បីប្រមូលព័ត៌មានអំពីអ្នកផលិតពិតប្រាកដ និងតម្រូវការហិរញ្ញវត្ថុពិតប្រាកដ ជាពិសេសសម្រាប់គម្រោងឥណទានផលិត-នាំចេញគម្រោងឥណទានផលិតកម្មនាំចេញឥណទានផលិតកម្មជំនួសសម្រាប់គម្រោងនាំចូល និងផ្សេងៗទៀត។ រដ្ឋាភិបាលបានកំណត់អតិផរណានៅកម្រិត៥%ទៅ៧%ក្នុងឆ្នាំ២០២២ហើយបានបង្កើតយន្តការអត្រាប្តូរប្រាក់ថ្មីមួយដើម្បីជៀសវាងភាពខុសគ្នានៃតម្លៃរូបិយប័ណ្ណរវាងអត្រាប្តូរប្រាក់ផ្លូវការ និងក្រៅផ្លូវការ៕

*ដោយ សេន ចន្ធី*

*ប្រភព៖laotiantimes.ចេញផ្សាយថ្ងៃទី២៣ខែវិច្ឆិកា ឆ្នាំ២០២១*

## សេដ្ឋកិច្ចសកល

### ក្រុមសមាជិកសភាមកពីគណបក្សប្រជាធិបតេយ្យ ជំរុញឱ្យលោកប្រធានាធិបតី Joe Biden បញ្ចេញប្រេងបម្រុង និងដាក់បម្រាមការនាំចេញប្រេង




*ប្រភព៖ Reuters ២០២១, រូបភាព៖ Dado Ruvic/Illustration/Files*

ក្រុមសមាជិកសភាមកពីគណបក្សប្រជាធិបតេយ្យ បានជំរុញឱ្យលោកប្រធានាធិបតី Joe Biden បញ្ចេញប្រេងពីស្តុកប្រេងបម្រុងយុទ្ធសាស្ត្រអាមេរិក (U.S. Strategic Petroleum Reserve) និងហាមឃាត់ការនាំចេញប្រេងយ៉ាងហោចណាស់ជាបណ្តោះអាសន្ន ដើម្បីជួយទប់ស្កាត់ការកើនឡើងនៃតម្លៃថាមពល។

តាមរយៈសារលិខិតមួយមកពីក្រុមសមាជិកគណបក្សប្រជាធិបតេយ្យដែលដឹកនាំដោយលោក Ro Khanna សមាជិកសភាមកពីរដ្ឋកាលីហ្វ័រញ៉ា បានស្នើឱ្យលោកប្រធានាធិបតី Biden ដាក់ចេញនូវវិធានការបន្ទាន់ដើម្បីធានា «ថាមពលដែលមានតម្លៃសមរម្យ និងអាចទុកចិត្តបានសម្រាប់ប្រជាពលរដ្ឋអាមេរិក»។ ជាមួយគ្នានេះ ក៏មានសារលិខិតមួយផ្សេងទៀតដែលចុះហត្ថលេខាដោយក្រុមសមាជិកសភាមកពីគណបក្សប្រជាធិបតេយ្យចំនួន ០៨រូប បានអំពាវនាវឱ្យលោកប្រធានាធិបតី Biden «ប្រើប្រាស់គ្រប់មធ្យោបាយដើម្បីកាត់បន្ថយថ្លៃប្រេងក្នុងរយៈពេលដ៏ខ្លី»។

ក្រុមសមាជិកសភា បានអះអាងថាការហាមឃាត់បណ្តោះអាសន្នលើការនាំចេញប្រេងនឹងជួយជំរុញការផ្គត់ផ្គង់ក្នុងស្រុក និងកាត់បន្ថយថ្លៃប្រេងដែលថ្មីៗនេះបានកើនឡើងដល់កម្រិតខ្ពស់ក្នុងរយៈពេល ៣១ឆ្នាំ ដោយមិនមានផលប៉ះពាល់ខ្លាំងដល់ទីផ្សារប្រេងសកលឡើយ។

ក្នុងសារលិខិតលោក Khanna បានបញ្ជាក់ថាការដោះស្រាយបញ្ហាអតិផរណា និងក្តីកង្វល់របស់ប្រជាពលរដ្ឋអាមេរិក គឺជាការទទួលខុសត្រូវរបស់សមាជិកសភានៃគណបក្សប្រជាធិបតេយ្យ ដែលបញ្ហានេះគឺជាហានិភ័យនៃការបាត់បង់ការគ្រប់គ្រងអំណាចសភាក្នុងការបោះឆ្នោតពាក់កណ្តាលអាណត្តិនៅឆ្នាំក្រោយ។ ដូច្នេះ «យើងត្រូវតែបញ្ជាក់ឱ្យបានច្បាស់ថាយើងកំពុងធ្វើអ្វីគ្រប់យ៉ាងដែលអាចធ្វើបាន ដើម្បីដោះស្រាយបញ្ហាអតិផរណា»។

លោកប្រធានាធិបតី Biden អាចនឹងពិភាក្សាអំពីបញ្ហាទាំងនេះ នៅអំឡុងពេលការថ្លែងសុន្ទរកថាស្តីពីសេដ្ឋកិច្ចអាមេរិក និងការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលរបស់លោក ដើម្បីកាត់បន្ថយការកើនឡើងនៃថ្លៃដើមនៅថ្ងៃអង្គារសប្តាហ៍នេះ បើយោងតាមប្រភពពីសេតវិមាន។ លោកប្រធានាធិបតី Biden មានសិទ្ធិអំណាចក្រោមច្បាប់ដើម្បីប្រកាសភាពអាសន្ន និងកំណត់ ឬបញ្ឈប់ការនាំចេញប្រេងរហូតដល់មួយឆ្នាំ បើទោះបីជាអ្នកជំនាញបាននិយាយថា ការធ្វើដូច្នេះមានកម្រិតតិចតួចក៏ដោយ៕ *ដោយ ស៊ិន សុភារ៉ា*

*ប្រភព៖ Reuters ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១*

## បញ្ហាប្រឈមនៃសង្វាក់ផ្គត់ផ្គង់សកល នឹងបន្តរហូតដល់យ៉ាងហោចណាស់ឆ្នាំ២០២៣ យោងតាមការព្យាករណ៍របស់ប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនផ្សាយពាណិជ្ជកម្មយក្ស Publicis Groupe




*ប្រភព៖ CNBC ២០២១*

សម្ពាធខ្សែសង្វាក់ផ្គត់ផ្គង់ដែលប៉ះពាល់ដល់សេដ្ឋកិច្ចសកល ទំនងជាមានរយៈពេលយ៉ាងហោចណាស់មួយឆ្នាំទៀត ហើយការកើនឡើងនៃអតិផរណាគឺជាលទ្ធផលនៃកង្វះខាតក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ នេះបើយោងតាមសម្តីលោក Maurice Levy ប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនផ្សាយពាណិជ្ជកម្មយក្ស Publicis Groupe។

សេដ្ឋកិច្ចនៅទូទាំងពិភពលោក កំពុងប្រឈមមុខនឹងកង្វះខាតទំនិញ និងកម្លាំងពលកម្ម ខណៈដែលតម្លៃឧស្ម័នធម្មជាតិនៅអឺរ៉ុប បានកើនឡើងដល់កម្រិតខ្ពស់ក្នុងរយៈពេលប៉ុន្មានខែថ្មីៗនេះ ដោយសារការកើនឡើងនៃតម្រូវការ អាកាសធាតុធ្ងន់ធ្ងរ និងស្តុកកាន់តែទាប។

លោកបានបញ្ជាក់ថា «វាក៏ជាការពិតដែលថាយើងកំពុងផ្លាស់ប្តូរទៅរកថាមពលបៃតង យើងកំពុងផ្លាស់ប្តូរទៅកាន់ពិភពបៃតង ប៉ុន្តែយើងមានការលំបាកក្នុងការទទួលបានថាមពលថ្មីនេះដល់កម្រិតនៃពិភពលោកចាស់» ដែលនេះគឺកំពុងបង្កើតឱ្យមានការកើនឡើងនៃតម្លៃ និងដាក់សម្ពាធលើអំណាចទិញរបស់អតិថិជន។

លោកបន្ថែមថា អតិផរណា និងបញ្ហាផ្គត់ផ្គង់នាពេលបច្ចុប្បន្នគឺឆ្លុះបញ្ចាំងពីដំណាក់កាលអន្តរកាល ហើយលោកព្យាករណ៍ថា ការវិលត្រឡប់ទៅរកប្រក្រតីភាពវិញ អាចកើតឡើងនៅក្នុងឆ្នាំ២០២៣ ឬ ២០២៤»។

ជាក់ស្តែង អតិផរណានៅសហរដ្ឋអាមេរិកបានកើនឡើង ៦,២% នៅក្នុងខែតុលា ឆ្នាំ២០២១ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដែលនេះជាការកើនឡើងដ៏ខ្ពស់បំផុតក្នុងរយៈពេលជាង ៣០ឆ្នាំ។ ខណៈ អតិផរណានៅតំបន់ចាយប្រាក់អឺរ៉ូនៅទូទាំងមហាសមុទ្រអាត្លង់ទិក បានកើនឡើងដល់ ៤,១% នៅក្នុងខែតុលា ឆ្នាំ២០២១ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដែលជាការកើនឡើងច្រើនជាងទ្វេដងនៃគោលដៅរបស់ធនាគារកណ្តាលអឺរ៉ុប។ ចំណែកឯ អតិផរណានៅចក្រភពអង់គ្លេស បានកើនឡើងដល់ ៤,២% នៅក្នុងខែតុលា ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន និងកើនឡើងពី ៣,១% កាលពីខែកញ្ញា ឆ្នាំ២០២១។

លោក Levy ក៏បានបន្ថែមទៀតថា វាជារឿងមិនត្រឹមត្រូវទេដែលត្រូវបង្កើនអត្រាការប្រាក់នៅពេលនេះ៕

*ដោយ ស៊ិន សុភារ៉ា*

*ប្រភព៖ CNBC ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១*

## ជប៉ុន ពិចារណាបញ្ចេញប្រេងក្នុងស្តុកបម្រុងដើម្បីបន្ធូរការហក់ឡើងនៃតម្លៃប្រេងឆៅសកល



*ដោយ sbm.news*

រដ្ឋាភិបាលជប៉ុន កំពុងពិចារណាបញ្ចេញប្រេងក្នុងស្តុកបម្រុងរបស់ខ្លួន ដើម្បីឆ្លើយតបនឹងការកើនឡើងនៃតម្លៃប្រេងឆៅនៅទូទាំងពិភពលោក។ នេះនឹងក្លាយជាលើកដំបូងបង្អស់ហើយ ដែលជប៉ុនបញ្ចេញប្រេងក្នុងស្តុកបម្រុងរបស់ខ្លួន ដើម្បីជួយបន្ធូរបន្ថយតម្លៃប្រេងឆៅ ទោះបីជាប្រទេសអាស៊ីមួយនេះ ក្នុងអតីតកាលធ្លាប់តែបញ្ចេញប្រេងពីស្តុកបម្រុងសម្រាប់តែករណីអាសន្ន ដូចជា ប្រទេសជប៉ុនគ្រោះធម្មជាតិ និងវិបត្តិភូមិសាស្ត្រនយោបាយតែប៉ុណ្ណោះ។ ការណ៍នេះបានកើតឡើងក្រោយរដ្ឋបាលអាមេរិក បានស្នើសុំប្រទេសប្រើប្រេងធំបំផុតរបស់ពិភពលោកមួយចំនួន ដូចជា ជប៉ុន ចិន និងឥណ្ឌា ជាដើម ឱ្យពិចារណាបញ្ចេញប្រេងពីស្តុកបម្រុងរបស់ខ្លួន សំដៅចូលរួមក្នុងកិច្ចប្រែងប្រឹងបន្ទាបតម្លៃថាមពលសកល ។

នៅតំបន់អាស៊ី ក្រៅពីជប៉ុន ប្រទេសចិន ក៏បានអះអាងថា ខ្លួនក៏កំពុងគិតគូរអំពីការបញ្ចេញប្រេងពីស្តុកបម្រុងខ្លួនផងដែរ។ យ៉ាងណាមិញ គេពុំទាន់ទទួលដំណឹងណាមួយពីរដ្ឋាភិបាលក្រុង ញូវដេលី នៅឡើយទេ តែឥណ្ឌា បានកាត់បន្ថយពន្ធដែលបង់ដោយអ្នកប្រើ

ប្រាស់លើប្រេងសាំង និងម៉ាស៊ូត ដើម្បីបន្ធូរបន្ថយការកើនឡើងតម្លៃ។

តម្លៃប្រេងបានកើនឡើងមួយកម្រិតទៀតនៅដើមខែវិច្ឆិកាកន្លងទៅ បន្ទាប់ពីក្រុមហ៊ុនផលិតប្រេងរដ្ឋរបស់អារ៉ាប៊ីសាអូឌីត Aramco បានដំឡើងតម្លៃប្រេងឆៅរបស់ខ្លួនជាផ្លូវការ ដោយមើលឃើញថាតម្រូវការនៅតែខ្ពស់ខណៈសង្វាក់ផ្គត់ផ្គង់កាន់រងការរំខាន៕ *ដោយម៉ែនខែមរៈ ប្រភព ៖ sbm.news ចេញផ្សាយថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២១។*

## សហរដ្ឋអាមេរិកដាក់សម្ពាធក្រុមប្រទេសផលិតប្រេង OPEC+ បូមប្រេងបន្ថែម



*ដោយ ខេមបូណ្ឌាមីស*

អាមេរិកបានដាក់សម្ពាធទៅលើក្រុមប្រទេសផលិតនាំចេញប្រេងធំៗ ឬហៅថា OPEC+ ដោយជំរុញឱ្យបូមប្រេងបន្ថែមឱ្យបានច្រើន និងកាត់បន្ថយតម្លៃប្រេងឆៅដែលកំពុងកើនឡើងខ្ពស់។ ប្រការនេះជាបញ្ហាថ្មីបន្ថែមទៀត សម្រាប់ក្រុមប្រទេសផលិតប្រេង ដ្បិតថា ពួកគេមិនមានលទ្ធភាពបន្ថែមដើម្បីបង្កើនទិន្នផលប្រេងរបស់ខ្លួនឱ្យបានលឿននោះទេ បើទោះបីជាពួកគេមានចិត្តចង់បង្កើនការបូមប្រេងក៏ដោយ។ OPEC+ កំពុងតែសម្រាលនូវវិធានការទប់ស្កាត់ការផ្គត់ផ្គង់ប្រេងរបស់ខ្លួន។ កាលពីឆ្នាំ២០២០ ដោយកាលនោះ ក្រុមប្រទេសទាំងនេះបានកាត់បន្ថយការផលិតប្រេង ដើម្បីរក្សាតម្លៃប្រេងឆៅកុំឱ្យធ្លាក់ចុះខ្លាំង ព្រោះតម្រូវការនាពេលនោះធ្លាក់ចុះដែរ។ បន្ទាប់ពីស្ថានភាពកូវីដ១៩ធូរស្បើយ តម្រូវការប្រេងកើនឡើងខ្ពស់ ប្រេងក៏ឡើងថ្លៃខ្លាំងណាស់ដែរមកទល់បច្ចុប្បន្ននេះ។

ក្រុមប្រទេសផលិតប្រេងទាំងអស់នោះ នៅតែប្រកាន់ខ្ជាប់នូវផែនការរបស់ពួកគេក្នុងការបង្កើនទិន្នផលជាបណ្តើរៗ ក្នុងចំនួន៤០ម៉ឺនបារ៉ែលក្នុងមួយថ្ងៃ ជារៀងរាល់ខែចាប់តាំងពីខែសីហាមក តែក្តីបារម្ភរបស់ពួកគេគឺប្រសិនបើពួកគេបង្កើនការបូមប្រេងលឿនពេក វានឹងធ្វើឱ្យមានទីផ្សារប្រេងនៅឆ្នាំ២០២២នឹងមានសភាពអាប់អួរឡើងវិញ ហើយវាក៏អាចរាំងស្ទះទៅដល់ផែនការបូមប្រេងរបស់ពួកគេផងដែរ។ បញ្ហាមួយទៀត ដែលប្រទេសផលិតប្រេងមិនអាចបង្កើនការបូមប្រេងបានលឿន គឺដោយសារតែការវិនិយោគនៅក្នុងផលិតកម្មប្រេងមានការធ្លាក់ចុះ ព្រោះតែវិបត្តិកូវីដ១៩ និងសម្ពាធបញ្ហាបរិស្ថានចំពោះក្រុមប្រទេសផលិតប្រេង ពិសេសនៅរដ្ឋក្រីក្រតែម្តង។ មានន័យថា មានត្រឹមតែសមាជិក៣ប៉ុណ្ណោះ នៃអង្គការ OPEC+ ដែលអាចបង្កើនសមត្ថភាពផ្គត់ផ្គង់ប្រេងបានលឿន គឺអារ៉ាប់ប៊ីសាអ៊ូឌីត, អេមេរ៉ាតអារ៉ាប់រួម, និងប្រទេសអ៊ីរ៉ាក់។

តម្លៃប្រេងឆៅនៅទីផ្សារអាមេរិក នៅថ្ងៃអង្គារសប្តាហ៍នេះ មានជិត៧៦ដុល្លារអាមេរិក ហើយនៅអង់គ្លេសជិត៧៩ដុល្លារអាមេរិក៕ *ដោយ ម៉ែន ខែមរៈ ប្រភព៖ខេមបូណ្ឌាមីសចេញផ្សាយថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១។*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១

- កំណើនសន្ទស្សន៍តម្លៃទំនិញប្រើប្រាស់នៅក្នុងប្រទេសអេស្ប៉ាញ ក្នុងខែតុលា ឆ្នាំ 2021
- ឱនភាពពាណិជ្ជកម្មរបស់ប្រទេសទួរគីបានរួមតូចយ៉ាងខ្លាំង ក្នុងខែកញ្ញា ឆ្នាំ 2021

ថ្ងៃអង្គារ ទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១

- អត្រាគ្មានការងារធ្វើរបស់ប្រទេសជប៉ុន នៅក្នុងខែកញ្ញា ឆ្នាំ 2021 មិនផ្លាស់ប្តូរ
- អត្រាអ្នកអត់ការងារធ្វើដែលបានកែសម្រួលតាមរដូវកាលនៅប្រទេសអាឡឺម៉ង់មានចំនួន 3.4%ក្នុងខែកញ្ញា ឆ្នាំ 2021

ថ្ងៃពុធ ទី០១ ខែធ្នូ ឆ្នាំ២០២១

- ការនាំចូលទៅកាន់ប្រទេសកូរ៉េខាងត្បូងបានកើនឡើង ក្នុងខែតុលា ឆ្នាំ 2021
- ការបង្កើតមូលធនថេរសរុបនៅក្នុងប្រទេសអូស្ត្រាលីបានកើនឡើង ក្នុងត្រីមាសទីពីរនៃឆ្នាំ 2021

ថ្ងៃព្រហស្បតិ៍ ទី០២ ខែធ្នូ ឆ្នាំ២០២១

- ការប៉ាន់ប្រមាណបឋមបានបង្ហាញថា សេដ្ឋកិច្ចរបស់ប្រទេសកូរ៉េខាងត្បូងបានកើនឡើង 0.3%នៅ ខែកញ្ញា ឆ្នាំ 2021
- ការនាំចូលទំនិញ និងសេវាកម្មទៅកាន់ប្រទេសអូស្ត្រាលីបានធ្លាក់ចុះ 2% ក្នុងខែកញ្ញា ឆ្នាំ 2021

ថ្ងៃសុក្រ ទី០៣ ខែធ្នូ ឆ្នាំ២០២១

- ផលិតផលក្នុងស្រុកសរុបរបស់ប្រទេសប្រេស៊ីលបានធ្លាក់ចុះ 0.1%នៅ ខែមិថុនា ឆ្នាំ 2021
- កំណើនអត្រាអតិផរណាប្រចាំឆ្នាំរបស់ប្រទេសអេស្ប៉ាញកើនឡើងយ៉ាងឆាប់រហ័សក្នុងរយៈពេលបួនខែជាប់គ្នា ក្នុងខែតុលា ឆ្នាំ 2021 ដែលជាកម្រិតខ្ពស់បំផុត៕